00945798

លេខ / No: D56/10

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**លេខសំណុំរឿង: ០០៣/០៧-០៩-២០០៩/អ.វ.ត.ក.--ក.ស.ច.ស.**

| | |
|---|---|
| ចំពោះមុខ ៖ | **ចៅក្រម យូ ប៊ុនឡេង** |
| | **ចៅក្រម Mark B. HARMON** |
| កាលបរិច្ឆេទ ៖ | **ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៣** |
| ភាសា ៖ | អង់គ្លេស |
| ចំណាត់ថ្នាក់ឯកសារ ៖ | **សម្ងាត់បំផុត** **ប្តូរទៅជាសាធារណៈ** |

# សេចក្តីសម្រេចលើសំណើរបស់សហមេធាវីសុំការអនុញ្ញាតបន្ថែមចំនួនទំព័រដែលបានកំណត់ និងដាក់ចម្លើយតបរបស់ពួកគាត់ជាភាសាអង់គ្លេស

**<u>ផ្ញើជូន</u>**

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Andrew CAYLEY

**<u>ចម្លងជូន</u>**

**សហមេធាវីដែលត្រូវបានតែងតាំង**
អាង ឧត្តម
Michael Karnavas

១. **បានឃើញ**ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពី អ.វ.ត.ក")

២. **បានឃើញ**វិធាន ២១ វិធាន ៣៩(៦) វិធាន ៥៥ និងវិធាន ៧២ នៃវិធានផ្ទៃក្នុង ("វិធានផ្ទៃក្នុង") និងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក ("សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ")

៣. **បានឃើញ**ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទាក់ទិននឹងសំណុំរឿង ០០៣[1] ដែលត្រូវបានដាក់ទៅក្នុងសំណុំរឿងនៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩[2]

៤. **បានឃើញ**ការបើកការស៊ើបសួរ ទាក់ទិននឹងការចោទប្រកាន់អំពីការរំលោភបំពានលើ**ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩** បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៣ (ថ្មី) មាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២០៩ មាត្រា ២១០ មាត្រា ៥០០ មាត្រា ៥០១ មាត្រា ៥០៣ មាត្រា ៥០៤ មាត្រា ៥០៥ មាត្រា ៥០៦ មាត្រា ៥០៧ និង មាត្រា ៥០៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦

## ពិភាក្សា

*ប្រវត្តិនីតិវិធី*

៥. នៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៣ សហមេធាវីដែលត្រូវបានតែងតាំងបានស្នើសុំការអនុញ្ញាតបន្ថែមចំនួនទំព័រដែលបានកំណត់ រួមជាមួយនឹងចម្លើយតបរបស់ពួកគាត់ទៅនឹងសារណាបន្ថែមស្តីពីជម្លោះផលប្រយោជន៍របស់សហមេធាវី ដែលត្រូវបានតែងតាំង ("ចម្លើយតប")។ នៅក្នុងសំណើដែលបានលើកឡើងនេះ និងអនុលោមតាមមាត្រា ៥.៤ និង

---

[1] សំណុំរឿងលេខ 003-D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨។

[2] សំណុំរឿងលេខ 003-D1/1 ការជូនដំណឹងអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ របស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩។

៧.២ នៃសេចក្តីណែនាំអនុវត្តជាធរមាន[3] សហមេធាវីដែលត្រូវបានតែងតាំងបានស្នើដល់សហចៅក្រមស៊ើបសួរអនុញ្ញាត ឲ្យពួកគាត់ដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសារណាបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិតែជាភាសាអង់គ្លេសប៉ុណ្ណោះ (ដោយដាក់សំណៅជាភាសាខ្មែរនៅពេលក្រោយ ឆាប់ៗតាមដែលអាចធ្វើបាន) និងបន្ថែមចំនួនទំព័រដែលបានកំណត់សម្រាប់ចម្លើយតបនេះ។

*ច្បាប់ជាធរមាន*

៦. វិធាន ៣៩(៦) នៃវិធានផ្ទៃក្នុង អានរួមគ្នាជាមួយមាត្រា ៥.១ និង ៥.៤ នៃសេចក្តីណែនាំអនុវត្តស្តីការដាក់ឯកសារ ចែងថា ឯកសារដាក់ទៅសហចៅក្រមស៊ើបអង្កេត មិនត្រូវលើសពី ១៥ទំព័រ ជាភាសាអង់គ្លេស លើកលែងតែ តាមការស្នើសុំរបស់ភាគី ចៅក្រមអាចពិចារណាបង្កើនចំនួនទំព័ររបស់ឯកសារនៅក្នុងកាលៈទេសៈពិសេស។

៧. មាត្រា ៧.២ សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ ចែងថា ៖ "*នៅក្នុងកាលៈទេសៈពិសេស សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះណាមួយនៃ អ.វ.ត.ក អាចអនុញ្ញាតឲ្យភាគីណាមួយដាក់ឯកសារជាភាសាបារាំង ឬភាសាអង់គ្លេសជាបឋមបាន ប៉ុន្តែបន្ទាប់មកភាគីត្រូវដាក់ឯកសារជាភាសាខ្មែរដែលបានបកប្រែរួច ឲ្យបានឆាប់របហ័សបំផុត*"។

*ទឡ្ហីករណ៍ធ្វើឡើងដោយភាគីដាក់ឯកសារ*

៨. អ្នកដាក់សំណើសុំបានស្នើសុំការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេត ដើម្បីដាក់សំណើដែលមានរហូតដល់ម្ភៃ (២០) ទំព័រ សរសេរជាភាសាអង់គ្លេស។

៩. សហមេធាវីដែលត្រូវបានតែងតាំងបានលើកឡើងថែមទៀតថា ប្រសិនបើសំណើសុំបន្ថែមចំនួនទំព័រដែលបានកំណត់មិនត្រូវបានអនុញ្ញាតឲ្យ សហមេធាវីដែលត្រូវបានតែងតាំងនឹងស្នើសុំពេលវេលាមួយថ្ងៃនៃថ្ងៃធ្វើការ ដើម្បីធ្វើការកោសលុប ឬកែសម្រួលចម្លើយតប។

[3] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ វិសោធនកម្មលើកទី៨។

១០. សហមេធាវីដែលត្រូវបានតែងតាំងក៏បានស្នើសុំការអនុញ្ញាត ដើម្បីដាក់ចម្លើយតបរបស់ខ្លួនដោយសរសេរតែជាភាសាអង់គ្លេសប៉ុណ្ណោះ ដោយដាក់សំណៅជាភាសាខ្មែរនៅពេលក្រោយឆាប់ៗតាមដែលអាចធ្វើបាន។

១១. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានទទួលយកសំណើសុំស្រដៀងគ្នានេះរួចហើយ ពីការិយាល័យសហព្រះរាជអាជ្ញា ពាក់ព័ន្ធទៅនឹងបញ្ហានេះ[4]។

១២. ផ្អែកលើកាលៈទេសៈពិសេសនៃករណីនេះ លក្ខណៈស្មុគស្មាញ និងសារៈសំខាន់នៃបញ្ហាដែលកំពុងស្ថិតនៅក្រោមការសម្រេច និងដោយពិចារណាឃើញថា ការអនុញ្ញាតឲ្យមានការបន្ថែមចំនួនទំព័រដែលបានកំណត់ នឹងមិនប៉ះពាល់ដល់ភាគីណាមួយ ឬដល់ការបំពេញកិច្ចស៊ើបសួររបស់តុលាការទេនោះ សំណើសុំដាក់ចម្លើយតបចំនួនម្ភៃ (២០) ទំព័រ សរសេរតែជាភាសាអង់គ្លេសប៉ុណ្ណោះ ដោយមានការដាក់សំណៅជាភាសាខ្មែរនៅពេលក្រោយឆាប់ៗតាមដែលអាចធ្វើបាន គួរតែត្រូវបានអនុញ្ញាត។

**ហេតុដូច្នេះ ខ្ញុំ MARK B. HARMON តាមរយៈនេះ÷**

១៣. **សម្រេច** ប្រកាសថា ការដាក់សំណើសុំអាចទទួលយកបាន និងដាក់ចម្លើយតបរបស់សហមេធាវីចូលក្នុងសំណុំរឿង ក្រោមឯកសារលេខ D56/9។

១៤. **អនុញ្ញាតតាម** សំណើសុំបន្ថែមចំនួនទំព័រដែលបានកំណត់ និងសំណើសុំដាក់ឯកសារតែជាភាសាអង់គ្លេសមួយប៉ុណ្ណោះ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៣

[ហត្ថលេខា និងត្រា]

**Mark B. Harmon**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

---

[4] សំណុំរឿង លេខ ០០៣ ឯកសារ D56/8 សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបន្ថែមចំនួនទំព័រដែលបានកំណត់ និងសុំដាក់សេចក្តីសន្និដ្ឋានរបស់ខ្លួនជាភាសាអង់គ្លេស ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៣។